- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **សហមេត្រី** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ និងមន្ត្រី នៃក្រសួងនគរបាលវៀតណាម ចំនួន១៥រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ**

| | |
|---|---|
| Senior Lieutenant General Le Quoc Hung | Deputy Minister of Ministry of Public Security ( MPS ) of Socialist Republic of Vietnam ។ |

ខ-មេដាយ **សហមេត្រី** ថ្នាក់ **សេនា**

| | |
|---|---|
| ១- Lieutenant General Dang Xuan Hong | Director General, Department of Foreign Relations, MPS |
| ២- Senior Colonel Nguyen Minh Phuong | Secretary to the Minister of MPS |
| ៣- Senior Colonel Vuong Quang Bac | Head of the Representative Office of MPS of Socialist Republic of Vietnam in the Kingdom of Cambodia |
| ៤- Senior Colonel Nguyen Minh Hieu | Deputy Director General, Department of Foreign Relations, MPS ។ |

គ-មេដាយ **សហមេត្រី** ថ្នាក់ **អស្សឫទ្ធិ**

| | |
|---|---|
| ១- Colonel Tran Anh Dung | Secretary to the Deputy Minister of MPS |
| ២- Senior Colonel Dao Ngoc Kien | Head of the Division of Southeast Asia, West Asia and South Asia, Department of Foreign Relations, MPS |
| ៣- Colonel Tran Viet Cuong | Head of the Division of Northeast Asia, Department of Foreign Relations, MPS |
| ៤- Colonel Ho Thi Hong Anh | Deputy Head of Division of Southeast Asia, West Asia and South Asia, Department of Foreign Relations, MPS |
| ៥- Lieutenant Colonel Vu Thi Phuong Thao | Deputy Head of the General Advisory Division, MPS |
| ៦- Lieutenant Colonel Nguyen Viet Hung | Officer, Foreign Affairs Protocol Division, Department of Foreign Relations, MPS |
| ៧- Lieutenant Colonel Do Hoanh Chien | Officer, Division of Southeast Asia, West Asia and South Asia, Department of Foreign Relations, MPS |
| ៨- Major Ngo Tien Cuong | Officer, General Advisory Division, MPS |

| | |
|---|---|
| ៩- Major Le Hoang Anh | Officer, Division of Southeast Asia, West Asia and South Asia, Department of Foreign Relations, MPS |
| ១០- Captain Tran Khac Nam | Officer, Division of Southeast Asia, West Asia and South Asia, Department of ForeignRelations, MPS ។ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤០១ សហវ.ប្រក.អគព

# ប្រកាស
## ស្តីពី
## ការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធឱ្យនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ
- បានឃើញប្រកាសលេខ ២១២ សហវ.ប្រក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ៩៦៧ សហវ. ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកែសម្រួលការិយាល័យជានាគុណភាព និងបណ្តុះបណ្តាល ទៅជាការិយាល័យធានាគុណភាព និងការិយាល័យបណ្តុះបណ្តាល នៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ
- បានឃើញប្រកាសលេខ ១៨៣ សហវ. ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធឱ្យនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ

## សម្រេច

**ប្រការ១._**

បង្កើតការិយាល័យបញ្ញាសិប្បនិម្មិត សរសេរជាអក្សរឡាតាំង Artificial Intelligence Bureau មានអក្សរកាត់ AIB ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ២._**

ការិយាល័យបញ្ញាសិប្បនិម្មិត មានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវអំពីឧត្តមានុវត្តន៍អន្តរជាតិពាក់ព័ន្ធនឹង ការអភិវឌ្ឍ និងប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីបង្កើនភាពឆ្លាតវៃ នៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងគ្រប់គ្រងការប្រមូលចំណូលពន្ធ
- ចូលរួមរៀបចំនិម្មាបនកម្ម ស្តីពីការអភិវឌ្ឍ និងប្រើប្រាស់បញ្ញាសិប្បនិម្មិតស្របតាមគោលការណ៍ ច្បាប់និងបទប្បញ្ញត្តិ និងឧត្តមានុវត្តន៍អន្តរជាតិតាមតម្រូវការជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ មុននឹងអនុវត្ត
- សិក្សាស្រាវជ្រាវ អភិវឌ្ឍ បង្វឹក និងធ្វើតេស្តម៉ូដែល (Machine Learning Models)និងក្បួនដោះស្រាយផ្នែកបញ្ញាសិប្បនិម្មិត (AI Algorithms) សម្រាប់ប្រើប្រាស់ដោយអគ្គនាយកដ្ឋានពន្ធដារ
- អភិវឌ្ឍ និងដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ញាសិប្បនិម្មិត ស្របតាមតម្រូវការជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ
- រៀបចំគោលការណ៍ស្តីពីការប្រើប្រាស់បញ្ញាសិប្បនិម្មិត ដែលរួមបញ្ចូលគោលការណ៍គន្លឹះស្តីពីក្រមសីលធម៌និងវិជ្ជាជីវៈ អនុលោមតាមស្តង់ដាការពារទិន្នន័យ និងការសម្ងាត់របស់អ្នកជាប់ពន្ធ ស្របតាមច្បាប់និងបទប្បញ្ញត្តិ និងឧត្តមានុវត្តន៍អន្តរជាតិ
- ប្រមូល និងទទួលព័ត៌មាន ឬទិន្នន័យដែលទាក់ទងនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងព្រឹត្តិការណ៍នានាដែលពាក់ព័ន្ធនឹងពន្ធដារ ព្រមទាំងបង្វឹកបញ្ញាសិប្បនិម្មិត ដើម្បីធ្វើបច្ចុប្បន្នកម្មព័ត៌មាន ឬទិន្នន័យទាំងនោះ ដើម្បីបច្ចុប្បន្នកម្មបញ្ញាសិប្បនិម្មិតដូចជា GDT Chatbot និង/ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ
- រៀបចំទិន្នន័យដែលទទួលបានទៅតាមចំណាត់ថ្នាក់ ប្រភេទ និងទម្រង់ឌីជីថលដែលបានកំណត់តាមស្តង់ដា ដើម្បីដាក់បញ្ចូលក្នុងម៉ូដែលបញ្ញាសិប្បនិម្មិត (AI Model) របស់អគ្គនាយកដ្ឋានពន្ធដារ
- គ្រប់គ្រង តាមដាន ដើម្បីធានាបាននូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត ស្របតាមតម្រូវការជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ

- រៀបចំយន្តការ និងប្រមូលជាតុចូលលើការប្រើប្រាស់បញ្ញាសិប្បនិម្មិតពីមន្ត្រីពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជនទូទៅដែលចាំបាច់សម្រាប់កែលម្អ និងបង្កើនសមត្ថភាពបញ្ញាសិប្បនិម្មិត
- បន្តពិនិត្យ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មាន និងទិន្នន័យដែលបានបញ្ចូលរួចក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារដូចជា GDT HomeTax - Cambodia Tax Administration System
- ចូលរួមរៀបចំផែនការសម្រាប់ការបង្កើន និងពង្រឹងសមត្ថភាពការប្រើប្រាស់បញ្ញាសិប្បនិម្មិត
- សហការ និងសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការ និងតាមតម្រូវការរបស់មន្ត្រីពន្ធដារ ធនាគារជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ និងអ្នកជាប់ពន្ធ លើការប្រើប្រាស់បញ្ញាសិប្បនិម្មិត្ត របស់អគ្គនាយកដ្ឋានពន្ធដារ
- គ្រប់គ្រង និងថែទាំសម្ភារការិយាល័យ និងសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យារបស់ការិយាល័យ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យជាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១០ កើត ខែ បឋមាសាឍ ឆ្នាំ មមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ការពិពណ៌នាមុខតំណែងចិជ្ជាជីវៈ

## អគ្គនាយកដ្ឋាន៖ អគ្គនាយកដ្ឋានពន្ធដារ

### ១- ការពិពណ៌នាមុខតំណែងមន្ត្រីជំនាញឯកទេសផ្នែកបញ្ញាសិប្បនិម្មិត

| | |
|---|---|
| ១- ឈ្មោះមុខតំណែង | មន្ត្រីជំនាញឯកទេសផ្នែកបញ្ញាសិប្បនិម្មិត |
| ២- ឈ្មោះអង្គភាព | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ៣- ឈ្មោះមុខតំណែងអ្នកគ្រប់គ្រងផ្ទាល់ | ប្រធានការិយាល័យបញ្ញាសិប្បនិម្មិត |
| ៤- គណនេយ្យភាព | រាយការណ៍ជូន៖ |

៥- តួនាទី ភារកិច្ច និងការទទួលខុសត្រូវនៃមុខតំណែង៖

មន្ត្រីជំនាញឯកទេសផ្នែកបញ្ញាសិប្បនិម្មិតមានតួនាទីចូលរួមអនុវត្តផែនការប្រតិបត្តិ និងផែនការសកម្មភាពរបស់ការិយាល័យបញ្ញាសិប្បនិម្មិត ដើម្បីសម្រេចបាននូវលទ្ធផលការងារប្រចាំថ្ងៃ។ ការទទួលខុសត្រូវសំខាន់ៗមានដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវអំពីឧត្តមានុវត្តន៍អន្តរជាតិពាក់ព័ន្ធនឹងការអភិវឌ្ឍ និងប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីចូលរួមចំណែកផ្តល់ធាតុចូលលើការបន្តអភិវឌ្ឍ បច្ចុប្បន្នកម្ម និងការបង្កើនភាពឆ្លាតវៃនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ
- សិក្សាស្រាវជ្រាវ អភិវឌ្ឍ បង្វឹក និងធ្វើតេស្តម៉ូដែល (Machine Learning Models) និងក្បួនដោះស្រាយផ្នែកបញ្ញាសិប្បនិម្មិត (AI Algorithms) សម្រាប់ប្រើប្រាស់ដោយអគ្គនាយកដ្ឋានពន្ធដារ
- ទាញយក វិភាគ និងរៀបរៀងសំណុំទិន្នន័យធំៗឱ្យបានត្រឹមត្រូវសម្រាប់ដាក់បញ្ចូលទៅក្នុងប្រព័ន្ធបញ្ញាសិប្បនិម្មិត
- អភិវឌ្ឍ និងដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ញាសិប្បនិម្មិត ស្របតាមតម្រូវការជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ
- តាមដាន វាយតម្លៃ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំរាល់ម៉ូដែល (Machine Learning Models) ដើម្បីធានាបាននូវសុក្រឹតភាព និងប្រសិទ្ធភាព
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការស្វែងរក និងកំណត់កាលានុវត្តភាពទាំងឡាយដើម្បីបង្កើនសមត្ថភាពប្រព័ន្ធបញ្ញាសិប្បនិម្មិតរបស់អគ្គនាយកដ្ឋានពន្ធដារ
- បង្កើត និងថែរក្សាឯកសារលម្អិតសម្រាប់ប្រព័ន្ធបញ្ញាសិប្បនិម្មិត និងសម្រាប់ពិសោធន៍នានា
- ចូលរួមរៀបចំនិម្មាបនកម្មស្តីពីការអភិវឌ្ឍ និងប្រើប្រាស់បញ្ញាសិប្បនិម្មិតស្របតាមគោលការណ៍ ច្បាប់និងបទប្បញ្ញត្តិ និងឧត្តមានុវត្តន៍អន្តរជាតិតាមតម្រូវការជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ មុននឹងអនុវត្ត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំ។

៦- គុណវុឌ្ឍិសម្រាប់មុខតំណែង (គុណសម្បត្តិស័ក្តិសម/លក្ខណៈសម្បត្តិស័ក្តិសមសម្រាប់មុខតំណែង)

- ក្របខ័ណ្ឌ ឋានន្តរសក្តិ (ករណីនេះអនុវត្តសម្រាប់តែមន្ត្រីរាជការស៊ីវិលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន)

| | |
|---|---|
| • ការបណ្តុះបណ្តាលផ្នែកជំនាញ | កម្រិតសញ្ញាបត្រ៖ បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល |
| | ជំនាញឯកទេស៖ វិទ្យាសាស្ត្រកុំព្យូទ័រ ឯកទេសផ្នែកបញ្ញាសិប្បនិម្មិត |

| | |
|---|---|
| • បទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង | យ៉ាងតិច ២ឆ្នាំ |
| • សមត្ថភាពបំពេញការងារ | ❖ ចំណេះដឹងនិងជំនាញ៖<br>- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅខាងផ្នែកឯកទេសបញ្ញាសិប្បនិម្មិត ឬប្រហាក់ប្រហែលពីសកលវិទ្យាល័យជំនាញឯកទេសផ្នែកបញ្ញាសិប្បនិម្មិត (AI)<br>- មានចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍបញ្ញាសិប្បនិម្មិត (AI) ដូចជាការបង្កើត Machine Learning/Deep Learning Models ក្នុងការដោះស្រាយបញ្ហាជាក់ស្តែង និងបម្រើឲ្យគោលបំណងជាក់លាក់ជាមួយស្ថាប័ន<br>- មានចំណេះដឹងអំពីភាសាធម្មជាតិនៃវិទ្យាសាស្ត្រកុំព្យូទ័រ NLP (Natural Language Processing)<br>- ចេះភាសាកម្មវិធី Python (ប្រើប្រាស់ Libraries ដូចជា Pandas, Scikit-learn, PyTorch ឬ TensorFlow), Java ឬ Golang និង C++ & R<br>- មានចំណេះដឹងស៊ីជម្រៅផ្នែកគណិតវិទ្យា ស្ថិតិ និងក្បួនដោះស្រាយ (Algorithms)<br>- មានចំណេះដឹងទូលំទូលាយលើក្របខណ្ឌ Machine Learning ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ គំនូរទិន្នន័យ និងនិម្មាបនកម្មសូហ្វវែរ (Software Architecture)<br>- មានភាពស្ទាត់ជំនាញ និងវៃឆ្លាតប្រឌិតក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកជុំវិញខ្លួន ព្រមទាំងអាចទំនាក់ទំនងដោយផ្ទាល់មាត់ និងសរសេរជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស<br>- មានស្មារតីការងារជាក្រុម ភាពច្នៃប្រឌិតក្នុងការវិភាគ និងដោះស្រាយបញ្ហា, ជំនាញគ្រប់គ្រងពេលវេលា, គំនិតផ្តួចផ្តើម និងអាចទទួលយកការបណ្តុះបណ្តាល។<br><br>❖ ឥរិយាបថបំពេញការងារ៖<br>- គោរពវិន័យ និងទទួលខុសត្រូវក្នុងការបំពេញការងារ<br>- មានឆន្ទៈម្ចាស់ការ ស្មោះត្រង់ មនសិការវិជ្ជាជីវៈ និងវប្បធម៌សាធារណៈ<br>- មានឆន្ទៈគាំទ្រ ចែករំលែកព័ត៌មានដល់បុគ្គលិករួមការងារ<br>- មិនរើសអើង ជាតិសាសន៍ ពណ៌សម្បុរ និងសាសនា និមានឆន្ទៈលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម<br>- មានសុខភាពល្អ<br>- ត្រូវមានអាកប្បកិរិយាទន់ភ្លន់ ថ្លៃថ្នូរ តែម៉ឺងម៉ាត់<br>- ត្រូវមានភាពរួសរាយរាក់ទាក់ រហ័សរហួន ប្រកបដោយគុណភាពសេវាកម្មវិជ្ជាជីវៈ<br>- មិនត្រូវប្រមាថ ចំអក សម្លុត គំរាមកំហែង ឬប្រើពាក្យសំដីមិនសមរម្យ<br>- មិនត្រូវជក់បារី សេពគ្រឿងស្រវឹង គ្រឿងញៀន លេងល្បែងស៊ីសង ឬការប្រព្រឹត្តអំពើអសីលធម៌<br>- មិនត្រូវយកអាវុធ គ្រឿងផ្ទុះ សារជាតិឆេះ និងវត្ថុធាតុ ឬសារធាតុដែលអាចបង្កគ្រោះថ្នាក់ក្នុងកន្លែងធ្វើការ<br>- ត្រូវអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ |

| | |
|---|---|
| | - មិនត្រូវឃុបឃិត ឬសមគំនិតជាមួយបុគ្គលផ្សេងទៀតក្នុងការគេចវេះ រារាំង និងបន្លំប្រាក់ពន្ធ<br>- មិនត្រូវស្នើសុំ ឬទទួលអំណោយ និងសំណូក ក្នុងទម្រង់ជាប្រាក់ សម្ភារ ទំនិញ ឬការផ្តល់អាទិភាព ឬគ្រឿងលើកទឹកចិត្តណាមួយ ដោយផ្ទាល់ ឬប្រយោល<br>- ត្រូវប្រកាន់ជំហរឯករាជ្យ និងមិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយអ្នកជាប់ពន្ធ<br>- ត្រូវធានាថារាល់របាយការណ៍ និងកំណត់ហេតុការងារពាក់ព័ន្ធមានភាពជាក់លាក់ច្បាស់លាស់ពិតប្រាកដ ទៀងត្រង់ មិនលំអៀង និងភាពទទួលខុសត្រូវខ្ពស់<br>- មិនត្រូវទទួលយកផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យឱនថយដល់ភាពសុចរិត និងស្មោះត្រង់ក្រៅពីអ្វីដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាអនុញ្ញាត<br>- មិនត្រូវទៅជួយរៀបចំបញ្ជិកាគណនេយ្យឱ្យអ្នកជាប់ពន្ធ<br>- មិនត្រូវប្រើតួនាទីផ្លូវការរបស់ខ្លួនដើម្បីមានឥទ្ធិពល ឬបង្វែរនូវនីតិវិធីរបស់រដ្ឋបាលសារពើពន្ធសម្រាប់ជាផលប្រយោជន៍របស់ខ្លួន គ្រួសារ មិត្តភក្តិ ឬបុគ្គលដទៃទៀត<br>- ត្រូវប្រកាន់ខ្ជាប់នូវការសម្ងាត់ និងព័ត៌មានដែលមានស្របតាមច្បាប់ស្តីពីសារពើពន្ធ<br>- ខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍ថ្មីៗសម្រាប់ការអភិវឌ្ឍអង្គភាព<br>- មានឆន្ទៈបំពេញការងារជាក្រុមប្រកបដោយស្មារតីសាមគ្គីភាពល្អ មានភាពបទបែន និងមិនមើលរំលងកំហុសខ្លួនឯង។ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៤២......សហវ.សភ.ភ.រ.សនជ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំ ប្រកាស ស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៣៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្ដីពី ការគ្រប់គ្រងថវិកា និង គណនេយ្យ របស់ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសរៀបចំប្រកាស ស្ដីពីនីតិវិធីនៃការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ។

**ប្រការ២.-**

ក្រុមការងារបច្ចេកទេសរៀបចំប្រកាស ស្ដីពីនីតិវិធីនៃការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ចាន់ សុធី** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម | **ហាច រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត | **ស្រី ឌុធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា | អនុប្រធាន |
| ៤- ឯកឧត្តម | **ម៉ិញ បានសុវណ្ណអាទិច្ចាសីលា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| ៥- លោក | **អៀង អូនទូច** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា | អនុប្រធានប្រចាំការ |
| ៦- ឯកឧត្តម | **សេខ ស្រេខ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ៧- លោក | **ហេង ស៊ីនឿន** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៨- លោក | **ឡាយ សុខឃៀង** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៩- លោក | **ឡាយ សុភ័ក្ត្រ** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១០- លោក | **ឡុង ចាន់តុលា** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១១- លោក | **ប៊ុន ឆាយ** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១២- លោក | **សាន សុខិដា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ១៣- លោក | **រិន ណារិទ្ធ** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៤- លោក | **ឌី សោភ័ណា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |

| | | | |
|---|---|---|---|
| ១៥- លោក | **ឈិន មូតា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៦- លោក | **ជុំ តុគ្រា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៧- លោក | **ហា សុគន្ធ** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១៨- លោក | **គឹម ខេមរាចេដ្ឋា** | បុគ្គលិកកិច្ចសន្យា នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |

**ប្រការ៣.-**

ក្រុមការងារបច្ចេកទេសរៀបចំប្រកាស ស្តីពីនីតិវិធីនៃការគ្រប់គ្រងថវិកា និងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស មានភារកិច្ចរៀបចំប្រកាសនេះ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣ អនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ និងបទដ្ឋានគតិយុត្តជាធរមាន ។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១០កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៤
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៤៣ ....សហវ. [illegible]

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ រាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៥៨ អ.ន.ក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៧៨៥ សហវ.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់រាជធានីភ្នំពេញ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ ១.-**

កែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ រាជធានីភ្នំពេញ ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ឃួង ស្រេង** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២. ឯកឧត្តម | **ឆាយ វីរៈ** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣. លោក | **ខឹម គុលា** | ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធានប្រចាំការ |
| ៤. លោក | **សារិន ចណ្ណា** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី នៃរាជធានីភ្នំពេញ | អនុប្រធាន |
| ៥. លោក | **ខ៉ែត លាភ** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៦. លោក | **ហោ វ៉ាន់ហ៊ីម** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧. លោកស្រី | **អេង សុថានី** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨. លោក | **យ៉េត កុលកិត្យា** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩. លោក | **ហ្វួង សុគន្ធា** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០. លោក | **កែ ពន្លក** | នាយករងរដ្ឋបាល នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ១១. **លោកអភិបាល នៃគណៈអភិបាលខណ្ឌ គ្រប់ខណ្ឌ** ក្នុងរាជធានីភ្នំពេញ | | | សមាជិក |
| ១២. **លោក លោកស្រី ប្រធានសាខាពន្ធដារខណ្ឌ គ្រប់ខណ្ឌ** ក្នុងរាជធានីភ្នំពេញ នៃអគ្គនាយកដ្ឋានពន្ធដារ | | | សមាជិក |
| ១៣. លោក | **វ៉ា សុធា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ | សមាជិក |
| ១៤. លោក | **ញ៉ៀម ធារារិទ្ធ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ | សមាជិក |
| ១៥. លោក | **ស្ទួស ឆមុន្នី** | នាយកទីចាត់ការហិរញ្ញវត្ថុ នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ១៦. លោក | **ទី ដូរី** | នាយកទីចាត់ការរៀបចំក្រុង នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ១៧. លោក | **នួន មាសចំរើន** | នាយករងទីចាត់ការហិរញ្ញវត្ថុ នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ១៨. លោក | **ព្រាប ពុទ្ធារ៉ា** | នាយករងទីចាត់ការហិរញ្ញវត្ថុ នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ១៩. លោក | **គោ ដេវីត** | ប្រធានការិ.គណនេយ្យ ទីចាត់ការហិរញ្ញវត្ថុ នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ២០. លោក | **លឹម ចាន់ថា** | ប្រធានការិ.ហិរញ្ញកិច្ច ទីចាត់ការហិរញ្ញវត្ថុ នៃសាលារាជធានីភ្នំពេញ | សមាជិក |
| ២១. លោក | **ស៊្វ សិទ្ធិ** | ប្រធានការិ.គ្រប់គ្រងទ្រព្យសម្បត្តិ ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ២២. លោក | **សៀន សុយ៉ានី** | ប្រធានការិ.សុរិយោដី នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ | សមាជិក |
| ២៣. លោក | **សុវណ្ណា សម្បូណ៌** | ប្រធានការិ.ពន្ធអចលនទ្រព្យទី១ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៤. លោក | **ពិសិដ្ឋ វាសនា** | ប្រធានការិ.ពន្ធអចលនទ្រព្យទី២ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៥. លោក | **ជុំ សាមីឌី** | ប្រធានការិ.ពន្ធចំណេញមូលធនទី១ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៦. លោក | **ច័ន្ទ ស៊ីថារ័ត្ន** | អនុប្រធានការិ.ហិរញ្ញកិច្ច ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ២៧. លោកស្រី | **ទិន សាវត្ថី** | អនុប្រធានការិ.ពន្ធប្រថាប់ត្រាទី២ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៨. កញ្ញា | **ធន រ៉ាវី** | អនុប្រធានការិ.ពន្ធអចលនទ្រព្យទី១ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានភារកិច្ចដូចខាងក្រោម ៖

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងរាជធានីភ្នំពេញ
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងរាជធានីភ្នំពេញ ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធ ដាក់ជូនគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីធ្លីមិនបានប្រើប្រាស់។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់រាជធានីភ្នំពេញ អាចរៀបចំបង្កើតក្រុមជំនួយការមួយដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ។

**ប្រការ ៤.-**

សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៥.-**

អនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ប្រការ ៦.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

សាមីតួនាទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំមមី អដ្ឋស័ក ព.ស ២៥[illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៦

**រដ្ឋលេខាធិការប្រចាំការ**

**ប្រធានគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់**

**បណ្ឌិតសភាចារ្យ ជូ ចិរជិត្ត**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ០៤៤......សហវ......

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ រាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៧៦ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៧៨៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យរាជធានីភ្នំពេញ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ ១.-**

កែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ រាជធានីភ្នំពេញ ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ឃួង ស្រេង** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២. ឯកឧត្តម **ឆាយ រិទ្ធិ:** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣. លោក **ខឹម តុលា** | ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធានប្រចាំការ |
| ៤. លោក **សារិន វណ្ណា** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី នៃរាជធានីភ្នំពេញ | អនុប្រធាន |
| ៥. លោក **ទ៉ែត លាភ** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៦. លោក **ហោ វ៉ាន់ហ៊ីម** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧. លោកស្រី **អេង សុផានី** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨. លោក **យ៉េត កុលភិត្យា** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩. លោក **ហួង សុគន្ធា** | អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០. លោក **កែ ពន្លក** | នាយករងរដ្ឋបាល សាលារាជធានីភ្នំពេញ | សមាជិក |
| ១១. លោកអភិបាល នៃគណៈអភិបាលខណ្ឌ គ្រប់ខណ្ឌ នៃរាជធានីភ្នំពេញ | | សមាជិក |
| ១២. លោក លោកស្រី ប្រធានសាខាពន្ធដារខណ្ឌ គ្រប់ខណ្ឌ ក្នុងរាជធានីភ្នំពេញ នៃអគ្គនាយកដ្ឋានពន្ធដារ | | សមាជិក |
| ១៣. លោក **វ៉ា សុធា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ | សមាជិក |
| ១៤. លោក **ញ៉ែម គារាវិទ្ធ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ | សមាជិក |
| ១៥. លោក **ស្មួស ឆមុន្នី** | នាយកទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ១៦. លោក **ទី ដូរី** | នាយកទីចាត់ការរៀបចំក្រុង សាលារាជធានីភ្នំពេញ | សមាជិក |
| ១៧. លោក **ឡូន មាសចំរើន** | នាយករងទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ១៨. លោក **ព្រាប ពុទ្ធារ៉ា** | នាយករងទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ១៩. លោក **តោ ដេវីត** | ប្រធានការិ.គណនេយ្យ ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ២០. លោក **លឹម ចាន់ថា** | ប្រធានការិ.ហិរញ្ញកិច្ច ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ២១. លោក **សូ សិទ្ធិ** | ប្រធានការិ.គ្រប់គ្រងទ្រព្យសម្បត្តិ ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ២២. លោក **សៀង សុយ៉ានី** | ប្រធានការិ.សុរិយោដី នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ | សមាជិក |
| ២៣. លោក **សុវណ្ណា សម្បូណ៌** | ប្រធានការិ.ពន្ធអចលនទ្រព្យទី១ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៤. លោក **ពិសិដ្ឋ វាសនា** | ប្រធានការិ.ពន្ធអចលនទ្រព្យទី២ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៥. លោក **ជុំ សាមីឌី** | ប្រធានការិ.ពន្ធចំណេញមូលធនទី១ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៦. លោក **ច័ន្ទ ស៊ីថារ័ត្ន** | អនុប្រធានការិ.ហិរញ្ញកិច្ច ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ | សមាជិក |
| ២៧. លោកស្រី **ទិន សាវត្ថី** | អនុប្រធានការិ.ពន្ធប្រថាប់ត្រាទី២ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២៨. កញ្ញា **ឆន រ៉ាវី** | អនុប្រធានការិ.ពន្ធអចលនទ្រព្យទី១ នៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរាជធានីភ្នំពេញ និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យសង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធលើអចលនទ្រព្យ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរាជធានីភ្នំពេញ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក និងជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យសង្កាត់
- សមាជិកអនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យរាជធានីភ្នំពេញ មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យសង្កាត់ ជាជំនួយការ។

ក្រុមការងារសង្កាត់ មានភារកិច្ច ដូចខាងក្រោម ៖

- ចូលរួមផ្តល់យោបល់ក្នុងការកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងទីតាំងក្នុងដែនសមត្ថកិច្ចរាជធានីភ្នំពេញ
- សហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ច ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ
- សហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- សហការការងារដទៃទៀតតាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ
- សមាជិកក្រុមការងារត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ ៤.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

សាមីតួនាទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០២៦

**រដ្ឋលេខាធិការប្រចាំការ**

**ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ**

**បណ្ឌិតសភាចារ្យ ជួ ចិវិត្ត**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខៈ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២៦

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៥៤៦/១៣ ម.ត.ស.ព ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ២០០/២៣ ម.ត.ស.ព ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការប្តូរនាមករណ៍ក្រុមហ៊ុនរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ របស់ក្រុមហ៊ុន ស៊ីអេសឃ្យូ អេស.អូខេ ហ្គាម៉ិន (ខេមបូឌា) ឯ.ក

### សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ីអេសឃ្យូ អេស.អូខេ ហ្គាម៉ិន** (ខេមបូឌា) ឯ.ក **(CSQ S. OK GARMENT (CAMBODIA) CO., LTD.)** តំណាងដោយលោកស្រី **SONG, XIAOFANG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EH5236098** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន (ស្វាយរៀង) (ភូមិថ្នាញ សង្កាត់បាទី ក្រុងបាវិត ខេត្តស្វាយរៀង) ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីអេសឃ្យូ អេស.អូខេ ហ្គាម៉ិន (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហានៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០៧៦ ឧវបន.កឱ.ប្រក. ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ និងលិខិតលេខ១៦៧៤ ឧវបន.កឱ.លស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**បណ្ឌិត ទឹម ស៊ីនី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-សាលាខេត្តស្វាយរៀង
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
-រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន (ស្វាយរៀង)
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី